ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder

ក្រសួងទេសចរណ៍

លេខ ០៨៧/ប្រក

087 ប្រក 16 5 16

ភ្នំពេញ, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០១៦

## ប្រកាស

## ស្តីពីឯកសណ្ឋានអ្នកវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ២០០៤ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
- យោងតាមសំណូមពរចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១._**

ប្រកាសនេះមានគោលបំណងកំណត់ឯកសណ្ឋានអ្នកវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ដែលបាននិងកំពុងអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២._**

ប្រកាសនេះមានគោលបំណង ដូចតទៅ:

- ធានា និងលើកកម្ពស់គុណភាពការងារ
- បង្កើនប្រសិទ្ធភាពការងារឱ្យបានកាន់តែល្អប្រសើរ
- បង្កើនការទុកចិត្តដល់ប្រតិបត្តិករទេសចរណ៍។

## ជំពូកទី២

## ទម្រង់ឯកសណ្ឋាន

**ប្រការ ៣._**

ឯកសណ្ឋានអ្នកវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ត្រូវកំណត់ដូចខាងក្រោម:

- អាវសឺមីដៃវែង និងដៃខ្លី មានផ្ទៃពណ៌បៃតងចាស់ មានហោប៉ៅពីរមានគំរប
- នៅលើដៃអាវខាងឆ្វេង ត្រូវមានស្លាកសញ្ញា របស់ក្រសួងទេសចរណ៍ដែលមានរាងមូល ហើយមានអង្កត់ផ្ចិតប្រវែង ៦ សម
- ខោជើងវែងបែបសកល ពណ៌កាគី សម្រាប់អ្នកវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ជាបុរស
- ខោជើងវែងបែបសកល ឬសំពត់បត់ក្រោមជង្គង់ ពណ៌កាគី សម្រាប់អ្នកវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ជានារី
- ត្រូវមានស្បែកជើងសមរម្យ(ហាមប្រើស្បែកជើងខ្សែចំពាម ឬស្បែកជើងសង្រែក)។

## ជំពូកទី៣

## ទម្រង់បណ្ណសម្គាល់ខ្លួន

**ប្រការ ៤._**

បណ្ណសម្គាល់ខ្លួនអ្នកវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍:

- មានប្រវែង ៩ សម និងកំពស់ ៥.៥ សម ។
- នៅផ្នែកខាងស្ដាំខាងមុខបណ្ណសម្គាល់ មានរូបថតទំហំ ៤ សម គុណនឹង ៦ សម
- មានបញ្ជាក់អំពីឈ្មោះ និងតួនាទី
- មាន (QR Code) ដែលអាចស្កេន (Scan)តាមរយៈស្មាតហ្វូន (Smart Phone)
- ផ្នែកខាងក្រោយ មានរូបសញ្ញា និងអក្សរដែលមានអត្ថន័យថា “**កម្ពុជា ព្រះរាជាណាចក្រអច្ឆរិយៈ**”
- ខ្សែស្លាកសញ្ញាត្រូវ មានទំហំ ១.៥ សម

ស្លាកសញ្ញាសម្គាល់ និងកាតសម្គាល់សម្រាប់អ្នកវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ដែលមានចែងខាងលើជាឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី៤

## ភារកិច្ចអ្នកវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ និងទណ្ឌកម្ម

**ប្រការ ៥._**

អ្នកវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ត្រូវស្លៀកពាក់ឯកសណ្ឋាន និងពាក់ស្លាកសញ្ញាសម្គាល់ ដែលបានកំណត់នៅពេលបំពេញបេសកកម្ម និងមិនអាចបំពានសិទ្ធិក្នុងការប្រើប្រាស់ឯកសណ្ឋានឡើយ។

**ប្រការ ៦._**

ក្នុងពេលបំពេញការងារ អ្នកវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍រូបណាមិនស្លៀកសំលៀកបំពាក់ឯកសណ្ឋាន និងពាក់សញ្ញាសម្គាល់ខ្លួនដែលបានកំណត់ខាងលើអាចនឹងត្រូវទទួលទណ្ឌកម្មដូចខាងក្រោម:

- ត្រូវដកហូតសិទ្ធិភ្លាមៗចេញពីបេសកកម្ម
- ទទួលទណ្ឌកម្មខាងរដ្ឋបាល(ការស្តីបន្ទោសដោយផ្ទាល់មាត់ ឬដោយលិខិត)
- ក្នុងករណីមិនរៀងចាល ប្រធានគ.វ.ចនឹងចេញសេចក្តីសម្រេចដកសិទ្ធិ និងតួនាទីអ្នកវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**ប្រការ ៧._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨._**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកទេសចរណ៍ នាយកខុទ្ទកាល័យ អធិការ ក្រុមអ្នកច្បាប់ ប្រធានគ្រប់នាយកដ្ឋាននៃក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្ត ត្រូវទទួលអនុវត្តតាមខ្លឹមសារប្រកាសនេះ អោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

*កន្លែងទទួល:*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ក្រសួងមហាផ្ទៃ*
- *ក្រសួងស្ថាប័នពាក់ព័ន្ធ*
- *អគ្គស្នងការនគរបាលជាតិ*
  *"ដើម្បីជ្រាបជាព័ត៌មាន"*
- *សាលារាជធានី-ខេត្ត*
- *ដូចក្នុងប្រការ ៨ "ដើម្បីអនុវត្ត"*
- *សមាគមសណ្ឋាគារ "ដើម្បីមុខការ"*
- *ឯកសារ-កាលប្បវត្តិ*

រដ្ឋមន្ត្រី

ថោង ខុន

# ឧបសម្ព័ន្ធ

## ស្ដីពីឯកសណ្ឋានអ្នកវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍

ប្រកាស លេខ...........ចុះថ្ងៃទី.........ខែ..........ឆ្នាំ ២០១៦

### ១. ឧបសម្ព័ន្ធទី១: ស្ដីពីឯកសណ្ឋាន

ប្រុស ស្រី ប្រុស ស្រី



### ២. ឧបសម្ព័ន្ធទី២: ស្ដីពីបណ្ណសម្គាល់ខ្លួន

ខ្សែកាត




ខាងមុខ




ខាងក្រោយ

